UNISDR
United Nations Office for Disaster Risk Reduction

Humanitarian Aid and Civil Protection

# Summary of the Sendai Framework for Disaster Risk Reduction 2015-2030

" Disaster risk reduction for our future "

## Scope and purpose

The present framework will apply to the risk of small-scale and large-scale, frequent and infrequent, sudden and slow-onset disasters, caused by natural or manmade hazards as well as related environmental, technological and biological hazards and risks. It aims to guide the multi-hazard management of disaster risk in development at all levels as well as within and across all sectors.

## Expected Outcome

The substantial reduction of disaster risk and losses in lives, livelihoods and health and in the economic, physical, social, cultural and environmental assets of persons, businesses, communities and countries.

## Goal

Prevent new and reduce existing disaster risk through the implementation of integrated and inclusive economic, structural, legal, social, health, cultural, educational, environmental, technological, political and institutional measures that prevent and reduce hazard exposure and vulnerability to disaster, increase preparedness for response and recovery, and thus strengthen resilience.

## TARGETS

- Substantially reduce global disaster mortality by 2030, aiming to lower average per 100,000 global mortality between 2020-2030 compared to 2005-2015
- Substantially reduce the number of affected people globally by 2030, aiming to lower the average global figure per 100,000 between 2020-2030 compared to 2005-2015
- Reduce direct disaster economic loss in relation to global gross domestic product (GDP) by 2030
- Substantially reduce disaster damage to critical infrastructure and disruption of basic services, among them health and educational facilities, including through developing their resilience by 2030
- Substantially increase the number of countries with national and local disaster risk reduction strategies by 2020
- Substantially enhance international cooperation to developing countries through adequate and sustainable support to complement their national actions for implementation of this framework by 2030
- Substantially increase the availability of and access to multi-hazard early warning systems and disaster risk information and assessments to the people by 2030. through adequate and sustainable support to complement their national actions for implementation of this framework by 2030

## GUIDING PRINCIPLES

- Primary responsibility of States to prevent and reduce disaster risk, including through cooperation
- Shared responsibility between central Government and national authorities, sectors and stakeholders as appropriate to national circumstances
- Coherence of disaster risk reduction and sustainable development policies, plans, practices and mechanisms, across different sectors
- Protection of persons and their assets while promoting and protecting all human rights including the right to development
- Accounting of local and specific characteristics of disaster risks when determining measures to reduce risk
- Engagement from all of society
- Addressing underlying risk factors cost-effectively through investment versus relying primarily on post-disaster response and recovery
- Full engagement of all State institutions of an executive and legislative nature at national and local levels
- «Build Back Better» for preventing the creation of, and reducing existing, disaster risk
- Empowerment of local authorities and communities through resources, incentives and decision-making responsibilities as appropriate
- The quality of global partnership and international cooperation to be effective, meaningful and strong
- Support from developed countries and partners to developing countries to be tailored according to needs and priorities as identified by them
- Decision-making to be inclusive and risk-informed while using a multi-hazard approach

## PRIORITIES FOR ACTION

There is a need for focused action within and across sectors by States at local, national, regional and global levels in the following four priority areas:

### Priority 1 Understanding disaster risk

Disaster risk management needs to be based on an understanding of disaster risk in all its dimensions of vulnerability, capacity, exposure of persons and assets, hazard characteristics and the environment.

### Priority 2 Strengthening disaster risk governance to manage disaster risk

Disaster risk governance at the national, regional and global levels is vital to the management of disaster risk reduction in all sectors and ensuring the coherence of national and local frameworks of laws, regulations and public policies that, by defining roles and responsibilities, guide, encourage and incentivize the public and private sectors to take action and address disaster risk.

### Priority 3 Investing in disaster risk reduction for resilience

Public and private investment in disaster risk prevention and reduction through structural and non-structural measures are essential to enhance the economic, social, health and cultural resilience of persons, communities, countries and their assets, as well as the environment. These can be drivers of innovation, growth and job creation. Such measures are cost-effective and instrumental to save lives, prevent and reduce losses and ensure effective recovery and rehabilitation.

### Priority 4 Enhancing disaster preparedness for effective response, and to «Build Back Better» in recovery, rehabilitation and reconstruction

Experience indicates that disaster preparedness needs to be strengthened for more effective response and ensure capacities are in place for effective recovery. Disasters have also demonstrated that the recovery, rehabilitation and reconstruction phase, which needs to be prepared ahead of the disaster, is an opportunity to «Build Back Better» through integrating disaster risk reduction measures. Women and persons with disabilities should publicly lead and promote gender-equitable and universally accessible approaches during the response and reconstruction phases.

UNISDR
United Nations Office for Disaster Risk Reduction

Humanitarian Aid
and Civil Protection

# សេចក្តីសង្ខេបអំពីក្របខ័ណ្ឌការងារសេនដាយសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ឆ្នាំ ២០១៥-២០៣០

**“ ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយសម្រាប់អនាគត ”**

## ទំហំការងារ និងគោលបំណង

ក្របខ័ណ្ឌ សេនដាយ គឺជាក្របខ័ណ្ឌសម្រាប់ឆ្លើយតបទៅនឹងហានិភ័យគ្រោះមហន្តរាយទ្រង់ទ្រាយតូច និងធំ ដែលមានលក្ខណៈញឹកញាប់ និងមិនញឹកញាប់ កើតឡើងភ្លាមៗ និងកើតឡើងក្នុងរយៈពេលវែង។ ហានិភ័យ បង្កដោយធម្មជាតិ ឬមនុស្ស ដែលទាក់ទងនឹងបរិស្ថាន បច្ចេកវិទ្យា និងជីវសាស្ត្រ។ ក្របខ័ណ្ឌនេះ មានគោលបំណងផ្តល់នូវគោលការណ៍ណែនាំអំពីការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ ដែលបង្កឡើងដោយមុខសញ្ញាគ្រោះថ្នាក់ច្រើន ក្នុងការអភិវឌ្ឍន៍ គ្រប់លំដាប់ថ្នាក់ ក៏ដូចជាគ្រប់ផ្នែកទាំងអស់។

## លទ្ធផលរំពឹងទុក

អាចកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការបាត់បង់ជីវិត ក៏ដូចជាផលប៉ះពាល់ដល់មុខរបរចិញ្ចឹមជីវិត និងសុខភាព ទាក់ទងធនធានសេដ្ឋកិច្ច រូបវ័ន្ត សង្គម វប្បធម៌ និងបរិស្ថានរបស់មនុស្ស អាជីវកម្ម សហគមន៍ និងប្រទេសជាតិទាំងមូល។

## គោលបំណងរួម

ការពារហានិភ័យគ្រោះមហន្តរាយថ្មីៗ និងកាត់បន្ថយហានិភ័យគ្រោះមហន្តរាយដែលធ្លាប់ជួបប្រទះ តាមរយៈការអនុវត្តវិធានការណ៍បញ្ជ្រាប និងមានការចូលរួមទាំងផ្នែកសេដ្ឋកិច្ច រចនាសម្ព័ន្ធ ច្បាប់ សង្គម សុខភាព វប្បធម៌ អប់រំ បរិស្ថាន បច្ចេកវិទ្យា នយោបាយ និងស្ថាប័ន ដែលអាចការពារ និងកាត់បន្ថយមុខសញ្ញាគ្រោះថ្នាក់ និងភាពងាយរងគ្រោះទៅនឹងគ្រោះមហន្តរាយ និងបង្កើនការត្រៀមបង្ការសម្រាប់ការឆ្លើយតប និងស្តារឡើងវិញ ដើម្បីពង្រឹងភាពធន់។

## សូចនាករ

- កាត់បន្ថយឲ្យបានជាអតិបរមានូវចំនួនអ្នករងផលប៉ះពាល់ ជាសកល នៅត្រឹមឆ្នាំ ២០៣០ ដោយកំណត់ទិសដៅកាត់បន្ថយចំនួនអ្នកទទួលរងផលប៉ះពាល់ជាសកលឲ្យស្ថិតនៅក្រោមកម្រិតមធ្យមមួយ ដោយគិតក្នុងចំនួនមនុស្ស ១00.000នាក់ នៅចន្លោះឆ្នាំ ២០២០ និង ២០៣០ ធៀបទៅនឹងចំនួនអ្នករងផលប៉ះពាល់ រវាងឆ្នាំ ២00៥ និង ២០១៥។
- កាត់បន្ថយឲ្យបានជាអតិបរមានូវចំនួនអ្នករងផលប៉ះពាល់ ជាសកល នៅត្រឹមឆ្នាំ ២០៣០ ដោយកំណត់ទិសដៅកាត់បន្ថយចំនួនអ្នកទទួលរងផលប៉ះពាល់ជាសកលឲ្យស្ថិតនៅក្រោមកម្រិតមធ្យមមួយ ដោយ គិតក្នុងចំនួនមនុស្ស ១00.000នាក់ នៅចន្លោះឆ្នាំ ២០២០ និង ២០៣០ ធៀបទៅនឹងអត្រាមរណៈ រវាងឆ្នាំ ២00៥ និង ២០១៥។
- កាត់បន្ថយការបាត់បង់ដោយផ្ទាល់ផ្នែកសេដ្ឋកិច្ច ទាក់ទងទៅនឹងផលិតផល ក្នុងស្រុកសរុបជាសកល នៅត្រឹមឆ្នាំ ២០៣០។
- កាត់បន្ថយឲ្យបានអតិបរមានូវការខូចខាត ដោយសារគ្រោះមហន្តរាយ ទៅលើហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ និងផលប៉ះពាល់ទៅលើសេវាកម្មមូលដ្ឋាន ដូចជាផ្នែកសុខភាព និងអប់រំជាដើម រួមទាំងការកសាងភាពធន់របស់វា នៅត្រឹមឆ្នាំ ២០៣០។
- បង្កើនចំនួនប្រទេសឲ្យបានច្រើន ដែលមានការរៀបចំយុទ្ធសាស្ត្រកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ នៅត្រឹមឆ្នាំ ២០២០។
- ពង្រឹងឲ្យបានខ្លាំងក្លានូវកិច្ចសហប្រតិបត្តិការអន្តរជាតិ ដល់ប្រទេសកំពុងអភិវឌ្ឍន៍តាមរយៈការគាំទ្រឲ្យបានគ្រប់គ្រាន់ និងមាននិរន្តរភាព ដើម្បីបំពេញបន្ថែមនូវសកម្មភាពថ្នាក់ជាតិ ដែលជាការចូលរួមចំណែក ដល់ការអនុវត្តក្របខ័ណ្ឌនេះ នៅត្រឹមឆ្នាំ ២០៣០។
- បង្កើនឲ្យបានខ្លាំងក្លា ក្នុងការបង្កើត និងផ្សព្វផ្សាយប្រព័ន្ធផ្តល់ព័ត៌មានជាមុន អំពីមុខសញ្ញាគ្រោះថ្នាក់ផ្សេងៗ រួមទាំងព័ត៌មាន និងរបាយការវាយតម្លៃអំពីហានិភ័យគ្រោះមហន្តរាយ ដល់ប្រជាពលរដ្ឋ នៅត្រឹមឆ្នាំ ២០៣០ តាមរយៈការគាំទ្រឲ្យបានគ្រប់គ្រាន់ និងមាននិរន្តរភាព ដើម្បីបំពេញបន្ថែមនូវសកម្មភាពថ្នាក់ជាតិ ដែលជាការចូលរួមចំណែក ដល់ការអនុវត្តក្របខ័ណ្ឌនេះ នៅត្រឹមឆ្នាំ ២០៣០។

## គោលការណ៍ណែនាំ

- ទំនួលខុសត្រូវបឋមរបស់រដ្ឋាភិបាល ដើម្បីការពារ និងកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ តាមរយៈកិច្ចសហប្រតិបត្តិការ។
- ទំនួលខុសត្រូវរួមរវាងរដ្ឋាភិបាលថ្នាក់ជាតិ អាជ្ញាធរជាតិ តាមផ្នែក និងភាគីពាក់ព័ន្ធ ដោយអាស្រ័យទៅតាមស្ថានភាពរបស់ប្រទេសសមាជិកនីមួយៗ។
- ភាពស៊ីសង្វាក់គ្នារវាងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការអភិវឌ្ឍន៍ ដោយចីរភាព ទាំងក្នុងគោលនយោបាយ ផែនការ ការអនុវត្ត និងយន្តការផ្សេងៗ លើគ្រប់វិស័យ។
- ការពារជីវិតមនុស្ស និងទ្រព្យសម្បត្តិ ដោយលើកកម្ពស់ និងការពារសិទ្ធិទាំងអស់របស់មនុស្ស រួមទាំងសិទ្ធិចូលរួមក្នុងការអភិវឌ្ឍន៍
- យកចិត្តទុកដាក់លើប្រភេទហានិភ័យគ្រោះមហន្តរាយ ជាក់លាក់ តាមតំបន់នីមួយៗ នៅពេលធ្វើការសម្រេចលើវិធានការឆ្លើយតប ដើម្បីកាត់បន្ថយហានិភ័យទាំងនោះ។
- សហការជាមួយដៃគូគ្រប់មជ្ឈដ្ឋាន
- ដោះស្រាយកត្តាដែលបង្កហានិភ័យឲ្យមានប្រសិទ្ធភាព តាមរយៈការវិនិយោគបន្ថែមទៅលើការឆ្លើយតបបឋម និងការស្តារឡើងវិញក្រោយគ្រោះមហន្តរាយ។
- សហការពេញលេញរវាងស្ថាប័នរដ្ឋទាំងអស់ ទាំងផ្នែកនីតិប្រតិបត្តិ និងនីតិបញ្ញត្តិ នៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន។
- ប្រកាន់គោលការណ៍ “កសាងឡើងវិញឲ្យប្រសើរជាងមុន” ដើម្បីបង្កើនការការពារ និងកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ។
- ផ្តល់សិទ្ធិអំណាចដល់អាជ្ញាធរមូលដ្ឋាន និងសហគមន៍ តាមរយៈការផ្តល់ធនធាន ការឧបត្ថម្ភធន និងទំនួលខុសត្រូវលើការសម្រេចចិត្ត តាមការដែលអាចធ្វើទៅបាន។
- ពង្រឹងគុណភាពដៃគូជាសកល និងកិច្ចសហប្រតិបត្តិការអន្តរជាតិ ប្រកបដោយប្រសិទ្ធភាព ត្រឹមត្រូវ និងខ្លាំងក្លា។
- មានការគាំទ្រពីប្រទេស និងដៃគូអភិវឌ្ឍន៍ ដល់ប្រទេសកំពុងអភិវឌ្ឍន៍ ដើម្បីឆ្លើយតបទៅនឹងតម្រូវការ និងអាទិភាព ដែលបានកំណត់។
- ការធ្វើសេចក្តីសម្រេចចិត្ត ត្រូវមានការចូលរួមពេញលេញ និងផ្អែកទៅតាមប្រភេទហានិភ័យនីមួយៗ។

## សកម្មភាពអាទិភាព

ប្រការចាំបាច់ គឺត្រូវយកចិត្តទុកដាក់ទៅលើសកម្មភាព អន្តរវិស័យ ដែលត្រូវអនុវត្តដោយរដ្ឋាភិបាលថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់អន្តរជាតិ ដោយផ្តោតទៅលើវិស័យអាទិភាពចំនួនបួនដូចខាងក្រោម ៖

### អាទិភាពទី១ ៖ ស្វែងយល់អំពីហានិភ័យគ្រោះមហន្តរាយ

ការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ គឺតម្រូវឲ្យមានការស្វែងយល់អំពីមុខសញ្ញាគ្រោះមហន្តរាយ នូវគ្រប់ស្ថានភាពរបស់វា ទាំងភាពងាយរងគ្រោះ សមត្ថភាព និងភាពប្រឈមរបស់មនុស្ស និងទ្រព្យសម្បត្តិ ប្រភេទមុខសញ្ញាគ្រោះថ្នាក់ និងបរិស្ថាន។

### អាទិភាពទី២ ៖ ពង្រឹងអភិបាលកិច្ចគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ

អភិបាលកិច្ចគ្រប់គ្រងហានិភ័យមហន្តរាយ នៅថ្នាក់ជាតិ តំបន់ និងថ្នាក់សកលលោក គឺជាកិច្ចការសំខាន់ ដែលត្រូវអនុវត្ត ដើម្បីគ្រប់គ្រងការកាត់បន្ថយហានិភ័យមហន្តរាយ នៅគ្រប់ផ្នែកទាំងអស់ និងត្រូវធានាឲ្យមានភាពស៊ីសង្វាក់គ្នារវាងក្របខ័ណ្ឌច្បាប់គតិយុត្តិ បទបញ្ញត្តិ និងគោលនយោបាយសាធារណៈ ថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន ដែលជាគោលការណ៍ណែនាំ លើកទឹកចិត្ត និងផ្តល់ការឧបត្ថម្ភធនដល់ផ្នែកសាធារណៈ និងឯកជន ក្នុងការអនុវត្តសកម្មភាព និងឆ្លើយតបនឹងហានិភ័យគ្រោះមហន្តរាយទៅតាមតួនាទី និងទំនួលខុសត្រូវ។

### អាទិភាពទី៣ ៖ ការវិនិយោគទៅលើការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ

ការវិនិយោគសាធារណៈ និងឯកជន ក្នុងការការពារ និងកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ តាមរយៈវិធានការណ៍ជាលក្ខណៈប្រព័ន្ធ និងមិនមានជាលក្ខណៈប្រព័ន្ធ គឺជាប្រការចាំបាច់ ដើម្បីពង្រឹងភាពធន់ផ្នែកសេដ្ឋកិច្ច សង្គម សុខភាព និងវប្បធម៌របស់មនុស្ស សហគមន៍ ប្រទេស និងធនធានរបស់ពួកគេ ក៏ដូចជាបរិស្ថានផងដែរ។ សកម្មភាពទាំងនេះ គឺជាកត្តាជំរុញដល់ភាពច្នៃប្រឌិត ការលូតលាស់ និងការបង្កើតការងារ។ វិធានការណ៍ទាំងនេះ គឺត្រូវគោរពតាមគោលការណ៍ប្រសិទ្ធភាពចំណាយ និងជាវិធានមួយ ដើម្បីសង្គ្រោះអាយុជីវិតមនុស្ស ការពារ និង កាត់បន្ថយភាពបាត់បង់ និងត្រូវធានាអំពីការស្តារ និងការកសាងឡើងវិញ ឲ្យមានប្រសិទ្ធភាព។

### អាទិភាពទី៤ ៖ ពង្រឹងវិធានការណ៍ត្រៀមបង្ការ សម្រាប់ការឆ្លើយតប ប្រកបដោយប្រសិទ្ធភាព និងសម្រាប់ការស្តារ រៀបចំ និងកសាងឡើងវិញ “ឲ្យប្រសើរជាងមុន”

បទពិសោធន៍បង្ហាញថា ការត្រៀមបង្ការទប់ទល់នឹងគ្រោះមហន្តរាយ គឺចាំបាច់ត្រូវពង្រឹង ដើម្បីឆ្លើយតបឲ្យមានប្រសិទ្ធភាពថែមទៀត និងត្រូវធានាឲ្យមានសមត្ថភាពដើម្បីស្តារឡើងវិញ ប្រកបដោយប្រសិទ្ធភាព។ គ្រោះមហន្តរាយ ក៏បានបង្ហាញដែរថា ដំណាក់កាលស្តារ រៀបចំ និងកសាងឡើងវិញ ដែលចាំបាច់ត្រូវត្រៀមមុនគ្រោះមហន្តរាយ គឺជាឱកាស ដើម្បី “ស្តារឡើងវិញឲ្យប្រសើរជាងមុន” តាមរយៈការបញ្ជ្រាបវិធានការណ៍កាត់បន្ថយហានិភ័យគ្រោះមហន្តរាយ។ ស្ត្រី និងជនពិការ គួរដើរតួឈានមុខ ក្នុងកិច្ចការសាធារណៈ ដើម្បីលើកកម្ពស់សមធម៌យេនឌ័រ និងចូលរួមជាសកល ក្នុងដំណាក់កាលឆ្លើយតប និងកសាងឡើងវិញ។